ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ ៩២៥១៧ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មការរៀបចំសទ្ទានុក្រមបច្ចេកសព្ទ ក្នុងវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៃក្រសួងមហាផ្ទៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១._**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការរៀបចំសទ្ទានុក្រមបច្ចេកសព្ទក្នុងវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៃក្រសួងមហាផ្ទៃ ដែលមានសមាសភាពនិងភារកិច្ច ដូចខាងក្រោម៖

១-ឯកឧត្តមនាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ ឯក មនោសែន ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ប្រធាន

២- ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យជំនួយ **យឹម សុវណ្ណាវុធ** អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អនុប្រធានអចិន្ត្រៃយ៍

| | | | |
|---|---|---|---|
| ៣- | តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ | | អនុប្រធាន |
| ៤- | តំណាងអគ្គនាយកដ្ឋានធនធានមនុស្ស | | អនុប្រធាន |
| ៥- | តំណាងអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ | | អនុប្រធាន |
| ៦- | តំណាងអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ | | អនុប្រធាន |
| ៧- | តំណាងអគ្គាធិការដ្ឋាន | | សមាជិក |
| ៨- | តំណាងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | | សមាជិក |
| ៩- | តំណាងក្រុមប្រឹក្សានីតិកម្ម | | សមាជិក |
| ១០- | តំណាងអគ្គនាយកដ្ឋានពន្ធនាគារ | | សមាជិក |
| ១១- | តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | | សមាជិក |
| ១២- | តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | | សមាជិក |
| ១៣- | តំណាងអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ | | សមាជិក |
| ១៤- | តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | | សមាជិក |
| ១៥- | តំណាងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | | សមាជិក |
| ១៦- | តំណាងគណៈកម្មការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ | | សមាជិក |
| ១៧- | តំណាងអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាកីឡា ក្រសួងមហាផ្ទៃ | | សមាជិក |
| ១៨- | តំណាងគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម | | សមាជិក |
| ១៩- | ឧត្តមសេនីយ៍ឯក បណ្ឌិត **អេង គឹមសាន** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា | សមាជិក |
| ២០- | ឧត្តមសេនីយ៍ឯក **ធឹង បុត្រ** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា | សមាជិក |
| ២១- | ឧត្តមសេនីយ៍ឯកបណ្ឌិត **ឡាយ សុបញ្ញា** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា | សមាជិក |
| ២២- | ឧត្តមសេនីយ៍ទោ បណ្ឌិត **ស្រៀង សុភី** | ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ | សមាជិក |
| ២៣- | ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យ បណ្ឌិត **វ៉េង សុធី** | គ្រូនគរបាលជាតិ | សមាជិក |
| ២៤- | ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង **នួន វិទ្យាស័ក** | គ្រូនគរបាលជាតិ | សមាជិក |
| ២៥- | ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យជំនួយ **កែវ មុនីរ័ត្ន** | គ្រូនគរបាលជាតិ | សមាជិក |
| ២៦- | ឧត្តមសេនីយ៍ទោ សាស្ត្រាចារ្យជំនួយ បណ្ឌិត **ឡេង បូរាណ** | គ្រូនគរបាលជាតិ | សមាជិក |
| ២៧- | ឧត្តមសេនីយ៍ឯក **ភុន សុផល** | នាយកសាលាមធ្យមវិជ្ជាជីវៈនគរបាល | សមាជិក |
| ២៨- | ឧត្តមសេនីយ៍ឯក **ពេជ្រ ពិសិដ្ឋ** | នាយកសាលាមធ្យមបច្ចេកទេស | សមាជិក |
| ២៩- | ឧត្តមសេនីយ៍ឯក **ឈឹម ថាណាវណ្ណ** | ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមន្ត្រីពន្ធនាគារ | សមាជិក |
| ៣០- | ឧត្តមសេនីយ៍ឯក **ហ៊ែល ធីរិទ្ធ** | នាយកវិទ្យាស្ថានគ្រប់គ្រងនិងបញ្ជាដឹកនាំ | សមាជិក |
| ៣១- | ឧត្តមសេនីយ៍ទោ បណ្ឌិត **ប៊ុន ភក្តី** | ប្រធានមន្ទីរចាត់ការ | សមាជិក |
| ៣២- | ឧត្តមសេនីយ៍ត្រី **ខែម សារី** | នាយកវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនគរបាល | សមាជិក |
| ៣៣- | វរសេនីយ៍ឯក បណ្ឌិត **កែប ប៊ុនលី** | នាយកវិទ្យាស្ថានក្រោយបរិញ្ញាបត្រ | សមាជិក |
| ៣៤- | វរសេនីយ៍ឯក **ទុំ សុគន្ធារ៉ូ** | ប្រធានដេប៉ាតឺម៉ង់ធានាគុណភាពអប់រំផ្ទៃក្នុង | សមាជិក |
| ៣៥- | វរសេនីយ៍ទោ **រិទ្ធ រ៉ាម៉ូ** | តំណាងវិទ្យាស្ថានព័ត៌មានវិទ្យានិងភាសាបរទេស | សមាជិក |
| ៣៦- | វរសេនីយ៍ឯក **ឈន់ សុខែម** | គ្រូនគរបាលជាតិ | សមាជិក |
| ៣៧- | វរសេនីយ៍ត្រី **ជួន ចេវ** | គ្រូនគរបាលជាតិ | សមាជិក |

| | | | |
|---|---|---|---|
| ៣៨- | វរសេនីយ៍ត្រី ហ៊ុន ប៉ោលាង | គ្រូនគរបាលជាតិ | សមាជិក |
| ៣៩- | វរសេនីយ៍ត្រី គៀល សេរីវុទ្ធ | គ្រូនគរបាលជាតិ | សមាជិក |

❖ **គណៈកម្មការនេះ មានភារកិច្ច ដូចខាងក្រោម៖**

- កំណត់បែបបទ នីតិវិធី និងលំហូរការងាររបស់លេខាធិការដ្ឋាន
- សហការនិងសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីប្រមូលមេពាក្យបច្ចេកសព្ទ និងនិយមន័យសម្រាប់រៀបចំសទ្ទានុក្រមនេះ ឱ្យបានពេញលេញ ត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ
- ពិនិត្យ កែសម្រួល ផ្តល់យោបល់ និងអនុម័តលើបច្ចេកសព្ទ និយមន័យ និងការបកប្រែជាភាសាអង់គ្លេសដោយសមាជិកគណៈកម្មការជំនាញនិងអ្នកជំនាញភាសាខ្មែរ
- ស្នើសុំថវិកាសម្រាប់គាំទ្រដំណើរការរៀបចំនិងបោះពុម្ពផ្សាយសទ្ទានុក្រមបច្ចេកសព្ទ ក្នុងវិស័យសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម
- រាយការណ៍អំពីលទ្ធផលការងារជាប្រចាំជូនប្រធានគណៈកម្មការនិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង
- លើកសំណើជូន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសឱ្យប្រើប្រាស់សទ្ទានុក្រមបច្ចេកសព្ទ ជាផ្លូវការ។

**ប្រការ២._**

ត្រូវបានបង្កើតអនុគណៈកម្មការបកប្រែភាសាអង់គ្លេសនិងលេខាធិការដ្ឋាន ចំណុះឱ្យគណៈកម្មការរៀបចំសទ្ទានុក្រមបច្ចេកសព្ទ ក្នុងវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដែលមានសមាសភាព និងភារកិច្ច ដូចខាងក្រោម៖

**១- អនុគណៈកម្មការបកប្រែភាសាអង់គ្លេស**

| | | | |
|---|---|---|---|
| ១- ឧត្តមសេនីយ៍ទោ | រស់ រក្សា | គ្រូនគរបាលជាតិ | ប្រធាន |
| ២- ឧត្តមសេនីយ៍ទោ | សុខ ណារ៉ុង | គ្រូនគរបាលជាតិ | អនុប្រធាន |
| ៣- ឧត្តមសេនីយ៍ទោ | ណិប ចាន់ថាវី | គ្រូនគរបាលជាតិ | អនុប្រធាន |
| ៤- ឧត្តមសេនីយ៍ត្រី | ហ៊ី សុផានិត | គ្រូនគរបាលជាតិ | សមាជិក |
| ៥- ឧត្តមសេនីយ៍ត្រី | ជៀប ឌីណា | គ្រូនគរបាលជាតិ | សមាជិក |
| ៦- វរសេនីយ៍ទោ | អេង សុផានិត | គ្រូនគរបាលជាតិ | សមាជិក |
| ៧- វរសេនីយ៍ត្រី | ឡុញ ពិសិដ្ឋ | គ្រូនគរបាលជាតិ | សមាជិក |
| ៨- អនុសេនីយ៍ត្រី | ភិន សុបញ្ញា | គ្រូនគរបាលជាតិ | សមាជិក |

❖ **អនុគណៈកម្មការនេះ មានភារកិច្ច ដូចខាងក្រោម៖**

- ពិនិត្យ ផ្ទៀងផ្ទាត់ និងកែតម្រូវការបកប្រែបច្ចេកសព្ទនីមួយៗ ជាភាសាអង់គ្លេស តាមការស្នើរបស់គណៈកម្មការរៀបចំសទ្ទានុក្រម
- រៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើការបកប្រែបច្ចេកសព្ទនីមួយៗ និង
- ធ្វើរបាយការណ៍ប្រចាំខែអំពីលទ្ធផលការងាររបស់ខ្លួន ជូនប្រធានគណៈកម្មការរៀបចំសទ្ទានុក្រម។

**២- លេខាធិការដ្ឋាន**

| | | | |
|---|---|---|---|
| ១- ឧត្តមសេនីយ៍ត្រី បណ្ឌិត | យ៉េន យ៉ាត | នាយកវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល | ប្រធាន |
| ២- ឧត្តមសេនីយ៍ទោ | នុត ប៊ុនធឿន | នាយករងវិទ្យាស្ថាន | អនុប្រធាន |
| ៣- ឧត្តមសេនីយ៍ទោ | លន ឈឿង | នាយករងវិទ្យាស្ថាន | អនុប្រធាន |
| ៤- ឧត្តមសេនីយ៍ទោ | ពេជ្រ ហួន | នាយករងវិទ្យាស្ថាន | អនុប្រធាន |

| | | | |
|---|---|---|---|
| ៥- ឧត្តមសេនីយ៍ត្រី | ចាន់ វណ្ណា | នាយករងវិទ្យាស្ថាន | អនុប្រធាន |
| ៦- ឧត្តមសេនីយ៍ត្រី | ធន ម៉េង | នាយករងវិទ្យាស្ថាន | អនុប្រធាន |
| ៧- ឧត្តមសេនីយ៍ត្រី | ភុន សុភារី | នាយករងវិទ្យាស្ថាន | អនុប្រធាន |
| ៨- ឧត្តមសេនីយ៍ត្រី | គង់ សុផល | នាយករងវិទ្យាស្ថាន | អនុប្រធាន |
| ៩- វរសេនីយ៍ឯក | ឃាន់ លឹមស្រ៊ាន់ | នាយករងវិទ្យាស្ថាន | អនុប្រធាន |
| ១០- វរសេនីយ៍ឯក | ប៉ែន មាន | នាយករងវិទ្យាស្ថាន | អនុប្រធាន |
| ១១- វរសេនីយ៍ឯក | គុប ធឿន | នាយករងវិទ្យាស្ថាន | អនុប្រធាន |
| ១២- វរសេនីយ៍ទោ | នង បញ្ញាកាយ | នាយករងវិទ្យាស្ថាន | អនុប្រធាន |
| ១៣- វរសេនីយ៍ឯក | រ័ត្ន វណ្ណធៃ | នាយការិយាល័យ | សមាជិក |
| ១៤- វរសេនីយ៍ឯក | ប៊ុន លី | នាយការិយាល័យ | សមាជិក |
| ១៥- វរសេនីយ៍ឯក | លៀង សៀវឃុន | នាយការិយាល័យ | សមាជិក |
| ១៦- វរសេនីយ៍ឯក | សុខ សុថាវី | នាយការិយាល័យ | សមាជិក |
| ១៧- វរសេនីយ៍ឯក | លុន កុសល | ប្រធានបណ្ណាល័យ | សមាជិក |
| ១៨- វរសេនីយ៍ទោ | ព្រំ សូលីដា | ប្រធានមន្ទីរពិសោធន៍ | សមាជិក |
| ១៩- វរសេនីយ៍ត្រី | គុន ថាវិទ្ធ | នាយការិយាល័យស្ដីទី | សមាជិក |
| ២០- អនុសេនីយ៍ឯក | ម៉ុន ទៀង | នាយផ្នែក | សមាជិក |

❖ **លេខាធិការដ្ឋាន មានភារកិច្ច ដូចខាងក្រោម៖**

- រៀបចំកិច្ចប្រជុំរបស់គណៈកម្មការរៀបចំសទ្ទានុក្រមបច្ចេកសព្ទ ក្នុងវិស័យសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមយ៉ាងតិចមួយដងក្នុងមួយខែ តាមជំនាញនីមួយៗ
- រៀបចំឧបករណ៍ សម្ភារៈ បម្រើឱ្យការងាររៀបចំសទ្ទានុក្រមទាំងមូល
- ធ្វើកំណត់ហេតុ ឬ របាយការណ៍អំពីលទ្ធផលការងាររបស់លេខាធិការដ្ឋាន
- លើកសំណើគម្រោងថវិកានិងគម្រោងចំណាយសម្រាប់ដំណើរការរបស់គណៈកម្មការ លើការប្រជុំសិក្ខាសាលា និងការបោះពុម្ពផ្សាយសទ្ទានុក្រម
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ជូនប្រធានគណៈកម្មការ និង
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធានគណៈកម្មការ។

**ប្រការ៣._**

អនុប្រធាន និងសមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សា គណៈកម្មាធិការ គណៈកម្មការ និងអង្គភាពដែលជាសមាជិក នៃគណៈកម្មការ មានសិទ្ធិជ្រើសរើសមន្ត្រីបន្ថែមតាមការឯកភាព របស់ប្រធានអង្គភាពសាមី ដើម្បីជួយការងារតាមការចាំបាច់។

**ប្រការ៤._**

សេចក្ដីសម្រេចលេខ ៦៣៧១ សសរ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ស្ដីពីការបង្កើតគណៈកម្មការរៀបចំសទ្ទានុក្រមបច្ចេកសព្ទ ក្នុងវិស័យសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ នៃក្រសួងមហាផ្ទៃ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.**_

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គាធិការ នៃអគ្គាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ប្រធានគណៈកម្មការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃអង្គារ ៣កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ

ក្រសួងមហាផ្ទៃ
បណ្ឌិត្យសភានគរបាលកម្ពុជា

លេខ: ........

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អល.មផ 3DB10E25

# សូមគោរពជូន

## ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**តាមរយៈ:** ឯកឧត្តមបណ្ឌិត រដ្ឋលេខាធិការទទួលបន្ទុក

**កម្មវត្ថុ:** សំណើសុំហត្ថលេខានិងប្រថាប់ត្រា លើការកែសម្រួលសមាសភាពនៃសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការរៀបចំសទ្ទានុក្រមបច្ចេកសព្ទក្នុងវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៃក្រសួងមហាផ្ទៃ។

**យោង:** សេចក្តីសម្រេចលេខ៦៣៧១ស.ស.រ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មការរៀបចំសទ្ទានុក្រមបច្ចេកសព្ទក្នុងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ នៃក្រសួងមហាផ្ទៃ។

អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
លេខចូល: 4559
ថ្ងៃចូល: 14.8.25 ម៉ោង 9:00
ថ្ងៃបញ្ជូន: ......

ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ចូល
លេខ: 2113
18.8.25

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមអភិសន្តិបណ្ឌិត** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ក្រសួងមហាផ្ទៃបានសម្រេចបង្កើតគណៈកម្មការរៀបចំសទ្ទានុក្រមបច្ចេកសព្ទក្នុងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៃក្រសួងមហាផ្ទៃ តាមការស្នើសុំពីប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងគោលបំណងដើម្បីកំណត់ការប្រើប្រាស់បច្ចេកសព្ទនិងនិយមន័យក្នុងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ឱ្យបានឯកភាពគ្នាទាំងការសរសេរ និងការបកស្រាយអត្ថន័យក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ។

ជាលទ្ធផល គណៈកម្មការបានដំណើរការនិងប្រមូលមេពាក្យបានចំនួន១ ៨៩៣ពាក្យ បានរៀបចំអង្គប្រជុំជាមួយអនុគណៈកម្មការជំនាញចំនួន៣៥លើក សម្រេចបានចំនួន២០៨ពាក្យ និងប្រជុំគណៈកម្មការអនុម័តសម្រេចជាផ្លូវការបានចំនួន៣៦ពាក្យ។ ប៉ុន្តែយោងតាមបរិការណ៍ជាក់ស្តែងគណៈកម្មការនេះមានការផ្លាស់ប្តូរសមាសភាពមួយចំនួន ដែលធ្វើឱ្យការរៀបចំសទ្ទានុក្រមត្រូវបានអាក់ខានមួយរយៈពេល។

ក្នុងន័យនេះ ដើម្បីជំរុញនិងបង្កើនប្រសិទ្ធភាពការងាររៀបចំសទ្ទានុក្រមបន្ត ខ្ញុំបាទសូមគោរពស្នើសុំគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអភិសន្តិបណ្ឌិត** ដើម្បីកែសម្រួលសមាសភាពគណៈកម្មការ និងគោរពស្នើសុំហត្ថលេខានិងប្រថាប់ត្រាលើសេចក្តីសម្រេច ដូចបានគោរពជូនភ្ជាប់ជាមួយ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអភិសន្តិបណ្ឌិត** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០២៥
**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **ឯក មនោសែន**

**បានឃើញ និងសូមគោរពជូន**
**ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។**
**រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០២៥**
**រដ្ឋលេខាធិការ**

បណ្ឌិត **នុច_វិសាលសុខ**